# ការណែនាំសម្រាប់បុគ្គលិកស្តារលទ្ធភាពពលកម្មតាមសហគមន៍/ ការអភិវឌ្ឍន៍បរិយាបន្ន័ CBR / CBID នៅក្នុងពេលមានជំងឺរាតត្បាតកូវីដ-១៩

**Guidance for CBR/CBID workers in the C0VID-19 pandemic**

បុគ្គលិកស្តារលទ្ធភាពពលកម្មតាមសហគមន៍/ ការអភិវឌ្ឍន៍បរិយាបន្ន័ CBR / CBID មានតួនាទីសំខាន់ណាស់ នៅក្នុងពេលមានជំងឺរាតត្បាតកូវីដ-១៩។ សកម្មភាពរបស់ពួកគេ អាចជួយការពារ និងគាំទ្រជនដែលមានពិការភាព ក្រុមគ្រួសារដែលមានសមាជិកពិការ និងសមាជិកដែលងាយរងគ្រោះ នៅក្នុងសហគមន៍។ បុគ្គលិកស្តារលទ្ធភាពពលកម្មតាមសហគមន៍/ ការអភិវឌ្ឍន៍បរិយាបន្ន័ CBR / CBID គួរតែចុះទៅសហគមន៍នានា សំរាប់គោលបំណងសំខាន់ៗដូចជាការផ្តល់អាហារ ទឹក ឬថ្នាំពេទ្យ។ នៅពេលនេះជាការសំខាន់ ដែលរក្សាគំលាតរាងកាយពីគ្នាកំឡុងពេលចុះទៅតាមសហគមន៍។ បុគ្គលិក CBR / CBID ត្រូវបានលើកទឹកចិត្ត ឱ្យទាក់ទងគ្រួសារ និងសមាជិកសហគមន៍តាមរយៈទូរស័ព្ទ (ផ្ញើសារ ឬតាម whats app) ជាទៀងទាត់។

សារ សំខាន់ៗដែលត្រូវបញ្ជូនដោយកម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍/ ការអភិវឌ្ឍន៍បរិយាបន្ន័ CBR / CBID នោះគឺ៖

- ដឹងអំពីគ្រោះថ្នាក់ / ហានិភ័យក្នុងស្រុក របស់លោកអ្នកទាក់ទងនឹងកូវីដ-១៩ ។
- រៀបចំផែនការរួមគ្នា ជាមួយសមាជិកសហគមន៍ អំពីអ្វីដែលត្រូវធ្វើ និងអ្នកដែលទទួលខុសត្រូវរាប់បញ្ចូលទាំងជនដែលមានពិការភាព និងសមាជិកងាយរងគ្រោះផ្សេងៗទៀត។
- ធ្វើឱ្យសហគមន៍របស់លោកអ្នកមានឆន្ទះ និងត្រៀមខ្លួនរួចរាល់
- ដឹងអំពីការផ្លាស់ប្តូរចំពោះស្ថានភាពនានា និងសម្របសម្រួលផែនការរបស់លោកអ្នកទៅតាមស្ថានភាពនោះ
- ឃ្លាំមើលគ្នាទៅវិញទៅមក និងចែករំលែកព័ត៌មាន

## ១. ដឹងពីគ្រោះថ្នាក់ / ហានិភ័យក្នុងស្រុករបស់លោកអ្នក

បុគ្គលិកសហគមន៍ ចាំបាច់ត្រូវស្គាល់ពីស្ថានភាពនៅក្នុងស្រុក។ បុគ្គលិកស្តារលទ្ធភាពពលកម្មតាមសហគមន៍/ ការអភិវឌ្ឍន៍បរិយាបន្ន័ CBR / CBID គួរតែដឹងពី ច្បាប់និងការអនុវត្តទាំងអស់ដែលកំណត់ដោយរដ្ឋាភិបាលក្នុងស្រុក និងធ្វើការរួមគ្នា ដើម្បីធានាថាតម្រូវការរបស់ជនដែលមានពិការភាព ត្រូវបានគេលើកឡើងពិចារណា ។

## ២. រៀបចំផែនការរួមគ្នាជាមួយសមាជិកសហគមន៍

នៅពេលដែលអាចមានការទំនាក់ទំនងតាមទូរស័ព្ទចំពោះគ្រួសារ និងបុគ្គលដែលអ្នកស្គាល់ និងរៀបចំផែនការរួមគ្នាជាមួយពួកគាត់ពីអ្វីដែលត្រូវធ្វើ និងអ្នកណាទទួលខុសត្រូវ។ ព្យាយាមធ្វើឱ្យប្រាកដថា តម្រូវការរបស់ជនដែលមានពិការភាព កំពុងត្រូវបានពិចារណាដាក់នៅក្នុងយុទ្ធសាស្ត្រមូលដ្ឋានដែលកំពុងត្រូវបានអនុវត្ត ជាឧទាហរណ៍៖

- អ្នកដែលមានជម្ងឺកូវីដ ១៩ មិនត្រូវបានគេមើលងាយដោយសហគមន៍របស់ពួកគាត់ទេ
- ធ្វើការយ៉ាងជិតស្និទ្ធជាមួយជនដែលមានពិការភាពទាំងអស់ និងក្រុមគ្រួសាររបស់ពួកគេ ដើម្បីធានាឲ្យទទួលបាននូវសេវាកម្មស្តារលទ្ធភាពពលកម្ម និងថ្នាំពេទ្យ នៅពេលចាំបាច់។
- ផ្តល់ទឹកស្អាត និងសាប៊ូសម្រាប់លាងដៃ ឱ្យបានទៀងទាត់ និងហ្មត់ចត់
- ដាក់ទីតាំងទឹកស្អាត និងសាប៊ូនៅតាមកន្លែងដែលអាចងាយស្រួលប្រើប្រាស់បាន
- ពាក់ម៉ាស់ នៅពេលចេញទៅក្រៅ និងនៅកន្លែងដែលមានមនុស្សច្រើន
- ផ្ញើសារឲ្យបានច្បាស់លាស់ អំពីគំលាតរាងកាយ (ចម្ងាយពីគ្នា ២ ម៉ែត្រ) និងការលាងដៃ
- មានការទាក់ទងទៅមណ្ឌលសុខភាព នៅពេលដែលអ្នកណាម្នាក់មានរោគសញ្ញានៃជម្ងឺកូវីដ-១៩

## ៣. ធ្វើឱ្យសហគមន៍របស់លោកអ្នកមានឆន្ទះ

សហគមន៍នឹងសំរេចចិត្តលើសកម្មភាពដែលពួកគេចង់ធ្វើ និងអាចមានលទ្ធភាពទទួលយកបាន ហើយអ្នកណាដែលនឹងទទួលខុសត្រូវ។ បុគ្គលិកសហគមន៍ អាចណែនាំក្រុមឱ្យធ្វើការសម្រេចចិត្តតាមជាក់ស្តែងពិតប្រាកដ។

## ៤. ត្រូវដឹងអំពីការផ្លាស់ប្តូរស្ថានភាពនានា និងសម្របសម្រួលផែនការរបស់លោកអ្នក

បុគ្គលិកសហគមន៍ ត្រូវទាក់ទងជាទៀងទាត់ជាមួយសហគមន៍ ដោយកត់សម្គាល់ថាតើស្ថានភាពកំពុងផ្លាស់ប្តូរយ៉ាងណាខ្លះនៅកម្រិតសហគមន៍ និងសម្រាប់បុគ្គល និងក្រុមគ្រួសាររបស់ពួកគាត់ និងផ្តល់ឱ្យពួកគាត់នូវព័ត៌មានថ្មីៗ អំពីការវិវត្តន៍បច្ចុប្បន្ន។

## ៥. ឃ្លាំមើលគ្នាទៅវិញទៅមក និងចែករំលែកព័ត៌មាន

ឃ្លាំមើលយកចិត្តទុកដាក់ចំពោះមិត្តរួមការងារ ជនដែលមានពិការភាព ចាស់ជរា និងអ្នកដឹកនាំសហគមន៍។ នេះគឺតាមរយៈការធ្វើការ និងចែករំលែកជាមួយគ្នាដែលជំងឺរាតត្បាតនេះអាចត្រូវបានគ្រប់គ្រងបាន។ វាមានសារៈសំខាន់ណាស់ សម្រាប់បុគ្គលិកសហគមន៍ក្នុងការរក្សាកំណត់ហេតុឲ្យបានល្អពី ប្រជាជន ទីកន្លែង ជម្ងឺ ភាពជោគជ័យ និងបញ្ហាប្រឈមនានាដូច្នេះព័ត៌មាននេះ អាចត្រូវបានរាយការណ៍យ៉ាងឆាប់រហ័ស និងត្រឹមត្រូវទៅកាន់អ្នកគ្រប់គ្រងស្ដារលទ្ធភាពពលកម្មតាមសហគមន៍ CBR អ្នកសម្របសម្រួល និងអាជ្ញាធររដ្ឋាភិបាល។

*សំរាប់ព័ត៌មានលម្អិតបន្ថែមសម្រាប់សកម្មភាពអាចរកបាននៅ៖*

https://www.who.int/publications-detail/disability-considerations-during-the-COVID-19-outbreak

*More details for action can be found at:* https://www.who.int/publications-detail/disability-considerations-during-the-COVID-19-outbreak



Produced by Professor Sally Hartley (UK) and Venkatesh Balakrishna (India) with contributions from Christine Cornick and the Zambian CBR/CBID team, Abdul Busuulwa CAN (Uganda) Professor Gwynneth Lelewellyn (Australia) Elanie Marks (Geneva, WHO)